**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការដ្ឋាន**

លេខ: ១១០ គ.ជ.ប.អគ្គ

ថ្ងៃសុក្រ ៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ស្ថានភាពទូទៅថ្ងៃចុងក្រោយ នៃការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ដែលជាថ្ងៃបិទបញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានគណបក្សនយោបាយ ចំនួន ១២ ក្នុងចំណោមគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត ទាំង ១៨ បានធ្វើសកម្មភាពឃោសនាបោះឆ្នោត ក្នុងនោះមានគណបក្សនយោបាយ ចំនួន ៤ បានហែក្បួនឃោសនារកសំឡេងឆ្នោត។

ទី១: គណបក្សប្រជាជនកម្ពុជា ហែក្បួនឃោសនានៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ចំនួន ២៤ មណ្ឌល តែពុំមានហែក្បួននៅមណ្ឌលខេត្តព្រះសីហនុទេ។ ទី២: គណបក្សហ្វ៊ុនស៊ិនប៉ិច ហែក្បួនឃោសនានៅមណ្ឌលរាជធានីភ្នំពេញ មណ្ឌលខេត្តកំពង់ចាម និងមណ្ឌលខេត្តកំពង់ស្ពឺ។ ទី៣: គណបក្សយុវជនកម្ពុជា ហែក្បួនឃោសនានៅមណ្ឌលខេត្តព្រៃវែង និងទី៤: គណបក្សខ្មែររួបរួមជាតិ ហែក្បួនឃោសនានៅមណ្ឌលរាជធានីភ្នំពេញ និងមណ្ឌលខេត្តកំពង់ចាម។

ចំណែកគណបក្សនយោបាយ ចំនួន ៨ ទៀតរួមមាន គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សធម្មាធិបតេយ្យ គណបក្សខ្មែរតែមួយ គណបក្សឯកភាពជាតិខ្មែរ គណបក្សសញ្ជាតិកម្ពុជា គណបក្សស្ត្រីដើម្បីស្ត្រី គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន បានធ្វើការឃោសនាបោះឆ្នោតតាមរយៈសកម្មភាពជួបប្រជុំជាមួយសមាជិក សកម្មជន និងអ្នកគាំទ្រគណបក្ស ចាក់មេក្រូផ្សព្វផ្សាយនៅទីស្នាក់ការគណបក្ស និងចល័តតាមភូមិ ចែកខិត្តបណ្ណតាមខ្ទង់ផ្ទះ បិទខិត្តបណ្ណ និងចងបដានៅតាមទីសាធារណៈ ប្រគំតន្ត្រី សម្តែងសិល្បៈ ចាក់បញ្ចាំងស្លាយ (Slide) វីដេអូ នៅតាមមណ្ឌលបោះឆ្នោតដែលខ្លួនឈរឈ្មោះ។

ជារួម ស្ថានភាពទូទៅនៃដំណើរការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនៅថ្ងៃចុងក្រោយ គិតត្រឹមម៉ោង ៦:០០ ល្ងាចនេះ បានប្រព្រឹត្តទៅដោយរលូន មានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ល្អ និងគ្មានអំពើហិង្សា។

អនុលោមតាមមាត្រា ៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត។ គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ អ្នកគាំទ្រគណបក្សនយោបាយ រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទ ត្រូវរក្សាភាពស្ងប់ស្ងាត់ ចាប់ពីម៉ោង ១០:០០យប់ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh